# កញ្ជើសុំសីល

ក្នុងវចនានុក្រមខ្មែរពន្យល់ពាក្យ "សីល" ជាវិរតិចេតនាដែលវៀរចាកអំពើអាក្រក់ ការកាន់ ឬប្រព្រឹត្តល្អដោយកាយ វាចា ការមិនប្រព្រឹត្តកន្លងសិក្ខាបទ ឬវិន័យបញ្ញត្តិ។[១] ការរក្សាសីលក្នុងព្រះពុទ្ធសាសនាមានបី គឺនិច្ចសីល ឬការរក្សាសីល៥ ឧបោសថសីល ឬការរក្សាសីល៨ និងអតិរេកសីល ឬការរក្សាសីល១០ ហើយក្នុងព្រះពុទ្ធសាសនាតែងទូន្មានពុទ្ធសាសនិករក្សាសីលឱ្យបានខ្ជាប់ខ្ជួន ដ្បិតសីលជាគ្រឿងលម្អមនុស្ស (សីលំ អភរណំ)។[២] ប៉ុន្តែនៅទីនេះ ខ្ញុំសូមមិនអធិប្បាយវែងឆ្ងាយអំពីការរក្សាសីលទាំងឡាយតាមពុទ្ធបញ្ញត្តិទេ។ ក្នុងអត្ថបទនេះ ខ្ញុំសូមលើកមកនិយាយអំពីវត្ថុ និងគ្រឿងបូជាសំខាន់ៗដែលអ្នករក្សាសីលប្រើ ហើយរៀបចំយ៉ាងវិសេសដាក់ក្នុងកញ្ជើមួយហៅថា "កញ្ជើសុំសីល"។

ខ្មែរពុំលំបាកយល់ឡើយពាក្យថា "កញ្ជើ" ដ្បិតយ៉ាងហោចយើងធ្លាប់សង្កេតឃើញអ្នកស្រែ ឬអ្នកចម្ការ ប្រើកញ្ជើសម្រាប់ដាក់ស្រូវអង្ករតមកជាហូរហែ។ កញ្ជើ ជាវត្ថុត្បាញពីបន្ទោះឫស្សី ក្ដាប់នឹងបន្ទោះផ្តៅ ឬវល្លិ ដែលមានរាងមូលនៅផ្នែកខាងលើហៅថាមាត់ និងខាងក្រោមរាបហៅថាបាត។ ប៉ុន្តែកញ្ជើសុំសីលដែលខ្ញុំលើកមករៀបរាប់នេះ ជាកញ្ជើសម្រាប់ដាក់តែរបស់របរ និងគ្រឿងសក្ការៈផ្សេងៗ ទុកប្រើប្រាស់រក្សាសីលតាមប្រតិភាពថ្ងៃសីលប្រចាំខែ និងការចូលទៅសមាទានសីលនៅតាមបុណ្យ ឬពិធីតូចធំនានាក្នុងពុទ្ធសាសនា។ កញ្ជើនេះ ខ្ញុំមានឱកាសឃើញក្នុងថ្ងៃបុណ្យរួមទួលតាមឿងពូនភ្នំខ្សាច់ របស់អ្នកស្រុកតំបន់អង្គរ ស្ថិតនៅទួលតាមឿង(អ្នកតា) ក្បែរវត្តអធ្វារ ខេត្តសៀមរាប។[៣] ផុតពីនោះ ឬនៅទីផ្សេង សូម្បីតែក្នុងខេត្តសៀមរាបដដែល ខ្ញុំឥតឱកាសបានឃើញទៀតឡើយ តែខ្ញុំក៏ពុំហ៊ានអះអាងដាច់ណាត់ថា នៅទីផ្សេង ឬនៅបុណ្យផ្សេងអ្នករក្សាសីលប្រើកញ្ជើសុំសីលនេះដូចនៅវត្តអធ្វារដែរ។

---

[១] ជួន ណាត និងអ្នកដទៃ ១៩៦៧: ១៣៩១

[២] បិដកលេខ៥៧ ទំព័រ២៨

[៣] បុណ្យនេះធ្វើរៀងរាល់ឆ្នាំនៅទួលតាមឿង (ទួលអ្នកតា) នៅរវាងខែពិសាខ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

កញ្ជើសុំសីលដែលខ្ញុំឃើញប្រើក្នុងឱកាសខាងលើ ជាប្រភេទកញ្ជើមានបាតខាងក្រោមជ្រុង(ជើង) ហើយមានលាបជ័រឈើ(ឬម្រ័ក្សរ?) យ៉ាងរលើបរលោង។ ខ្ញុំសង្កេតឃើញតែដូនជីស្លៀកសពាក់សប៉ុណ្ណោះ ដែលប្រើកញ្ជើសុំសីល។ រីឯតាជីដែលរក្សាសីលដូចគ្នាពុំឃើញប្រើកញ្ជើទាំងនោះឡើយ ពោលគឺប្រើត្រឹមតែថង់យាមមួយគត់។ ប៉ុន្តែយ៉ាងណាក៏ដោយ អ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺវត្ថុដែលផ្ទុកក្នុងកញ្ជើនេះទៅវិញទេ ដ្បិតវត្ថុខ្លះកើតឡើងដោយកិច្ច វត្ថុខ្លះជាគ្រឿងសក្ការៈសម្រាប់បូជា និងវត្ថុខ្លះបង្ហាញឱ្យឃើញពីទំនៀមទម្លាប់ ព្រមទាំងមានន័យខ្លឹមសារជ្រៅហួសពីអ្វីដែលខ្ញុំយល់ផងក៏មាន។

វត្ថុសំខាន់បំផុតខ្លះពុំបាននៅក្នុងកញ្ជើសុំសីលនេះ គឺឧបចារ[២] ឧបចារមានពងសណ្ឋានប្រហាក់ប្រហែលជើងពាន ហើយផ្នែកខាងលើធ្វើពីលាជ័ដូង ខាត់សម្អាតយ៉ាងរលោង។ នៅលើមាត់ឧបចារនេះ មានកន្លែងសម្រាប់បិទទៀន ដោតធូប ឬផ្កាឈូកអំឡុងពេលសមាទានសីល។ ក្នុងឧបចារនេះមានវត្ថុសំខាន់ៗពីរទៀតគឺ "គ្រាប់អដ្ឋ" ដែលយើងស្គាល់ជាទូទៅថាផ្តាំ និងវត្ថុមួយទៀតមានសណ្ឋានជាក្រដាសរុំជុំវិញវត្ថុប្រាំយ៉ាងគឺ ទៀន ធូប ម្លូ ស្លា និងបារី ហើយអ្នកស្រុកហៅថា "ខន្ធប្រាំ"។ គេពន្យល់យ៉ាងខ្លីថា គ្រាប់អដ្ឋគឺទុកសម្រាប់ចម្រើនអដ្ឋ ហើយខន្ធប្រាំតំណាងឱ្យខន្ធទាំងប្រាំរបស់មនុស្ស។ ខន្ធប្រាំត្រូវធ្វើដោយគ្រូត្រឹមត្រូវ ហើយចងដោយចំណងអំបោះឆៅបីកន្លែង គឺដើម កណ្តាល និងចុង។ វត្ថុនេះសំខាន់បំផុត ហើយបើបាត់បង់ ឬខូចខាតត្រូវទៅសុំពីគ្រូម្តងទៀត។[៣]

សរុបមកកញ្ជើសុំសីលនេះជាវត្ថុពិសេសសម្រាប់ដូនជីរក្សាសីលដាក់វត្ថុ និងគ្រឿងបូជាផ្សេងៗ សម្រាប់បំពេញឱ្យការរក្សាសីលមានភាពងាយស្រួល ដ្បិតក្រោយចប់ពិធីគេសង្កេតឃើញដូនជីខ្លះទូល ខ្លះកណ្តៀត ហើយដូនជីខ្លះដែលនៅមានកម្លាំងចំណាប់ផាក់កង់ ក៏ដាក់កញ្ជើសុំសីលនោះចងដឹកខាងក្រោយដែរ ពោលគឺហាក់ដូចជាធ្វើតាមទម្លាប់

---

[២] ពាក្យនេះខ្ញុំសរសេរតាមសម្តីអ្នកស្រុក ឯពាក្យដើមបំផុតខ្ញុំពុំដឹងសរសេរដូចម្តេចឡើយ។

[៣] គ្រូក្នុងពេលនេះ ពិបាកនឹងយកពាក្យអ្វីមកពន្យល់ តែហាក់ដូចជាចង់សំដៅលើអ្នកធ្លាប់បួសរៀន ឬអ្នកដែលចេះកម្មដ្ឋានច្បាស់លាស់។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*អត្ថបទ៖ កញ្ជើសុំសីល*

*និស្ស័យជាស្ត្រីអ្នកស្រុកអ្នកស្រែ។ ទន្ទឹមនឹងនេះ នៅក្នុងញ្ជើសុំសីលឃើញមានទាំងទៀន ធូប ម្ហូស្លា និងទឹកមួយដប។ វត្ថុទាំងអស់ចុងក្រោយនេះទុកសម្រាប់ប្រើប្រាស់ និងទទួលទានតាមទម្លាប់(ម្ហូស្លា)។ ដូច្នេះការរៀបចំរណ្តាប់នេះពុំមែនមានកំណត់នៅក្នុងបញ្ញត្តិពុទ្ធសាសនាឡើយ។ ប៉ុន្តែវត្ថុសំខាន់ៗ ដែលយើងសង្កេតឃើញនៅក្នុងនោះហាក់ដូចជាពិសេសសម្រាប់ការធ្វើសមាធិ ឬធ្វើកម្មដ្ឋាន៕*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

# បញ្ជីរូបភាព



រូបលេខ២១ ដូនជីអញ្ជើញចូលរួមពិធីបុណ្យនៅទួលតាមឿង ក្បែរវត្តអធ្វារ ខេត្តសៀមរាប





រូបលេខ២២ និងលេខ២៣ ដូនជីរៀបចំអុជទៀនធូប និងគ្រឿងបូជាព្រះរតនត្រៃ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៤ ជូនជីផ្ញើកិច្ចនមស្ការក្បែរកញ្ជើសុំសីលរៀងខ្លួន



រូបលេខ២៥ រណ្ដាប់សំខាន់ៗក្នុងឧបចារ



រូបលេខ២៦ ខន្ធប្រាំ



រូបលេខ២៧ ផ្កាំ ឬគ្រាប់អជ្ឈ



រូបលេខ២៨ ការរាប់គ្រាប់ផ្កាំចម្រើនអជ្ឈ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ៩ និងរូបលេខ១០ ដូនជីទូល និងកណ្ដៀតកញ្ជើសុំសីលរៀងៗខ្លួន




រូបលេខ១១ និងរូបលេខ១២ ដូនជីដឹកកញ្ជើសុំសីលរៀងខ្លួនត្រឡប់ទៅផ្ទះវិញ

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

*ជួន ណាត និងសការី*

១៩៦៧, *វចនានុក្រមខ្មែរ*, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*